សម្រេចអនុញ្ញាតបន្ថែមឱ្យ វិទ្យុសំឡេងសហរដ្ឋអាមេរិក ជាខេមរភាសា ចាក់ផ្សាយតាមស្ថានីយ៍ក្នុងស្រុកចំនួន៣ ដែលកម្លាំងផ្សាយគ្របដណ្តប់យ៉ាងហោចណាស់ខេត្តចំនួន១៧ ក្នុងចំណោមខេត្ត-រាជធានីទាំង២៥ ស្មើនឹងយ៉ាងហោចណាស់ ៦០% នៃប្រជាជនសរុប។ នៅប្រទេសកម្ពុជា មានអ្នកប្រើប្រាស់ Facebook ចំនួនជាង១០ លាន គណនី ដែលស្មើនឹង៦៥% នៃចំនួនប្រជាជនសរុប។ Facebook ជាវេទិកាសង្គមដ៏មានឥទ្ធិពលនិងប្រជាប្រិយខ្លាំង សម្រាប់ផ្សព្វផ្សាយព័ត៌មានភ្លាមៗ និងបញ្ចេញមតិជាសាធារណៈដោយសេរី។ អត្រាជ្រៀតចូលរបស់អ៊ីនធឺណែតមានចំនួន៦០% នៅទូទាំងប្រទេស ហើយមិនបានជួបប្រទះនឹងការកាត់ផ្តាច់ ឬការកម្រិតដែនកំណត់ ដូចដែលអ្នករាយការណ៍ពិសេសបានលើកឡើងដោយមិនត្រឹមត្រូវ នោះឡើយ។

បើនិយាយពីស្តង់ដារអន្តរជាតិវិញ អ្នករាយការណ៍ពិសេសពុំធ្លាប់ដែលបានសង្កត់ធ្ងន់ឱ្យបានគ្រប់គ្រាន់ទាល់តែសោះថា ការអនុវត្តសិទ្ធិត្រូវភ្ជាប់មកជាមួយនូវករណីយកិច្ច ការទទួលខុសត្រូវពិសេស និងដែនកំណត់ចែងដោយច្បាប់ ដូចបានគូសបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ។ ការខកខានមិនបានបញ្ជាក់ឱ្យបានច្បាស់ដោយចេតនាបែបនេះ ធ្វើឱ្យបុគ្គលបំពានច្បាប់កាន់តែគឃ្លើនក្នុងការកេងចំណេញពីស្ថានភាពដ៏គ្រោះថ្នាក់បែបនេះ សម្រាប់របៀបវារៈលាក់កំបាំងរបស់ពួកគេ ។

បើគេចាត់ទុកការអនុវត្តច្បាប់ជាការរឹតត្បិតសេរីភាព នោះគឺជាការបន្ទាបតម្លៃនីតិរដ្ឋ និងគោលការណ៍អនុវត្តស្មើភាពគ្នាចំពោះពលរដ្ឋទាំងអស់ ដែលបានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺការពារពលរដ្ឋគោរពច្បាប់ និងធានាអោយបាននូវសណ្តាប់ធ្នាប់សង្គម ការជឿជាក់ជាសាធារណៈ និងសុខភាពសារធារណៈ សម្រាប់មនុស្សគ្រប់ៗគ្នា។

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា សូមបញ្ជាក់ជាថ្មីនូវការបន្តការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ ហើយទទូចឱ្យអ្នករាយការណ៍ពិសេស ប្រកាន់យកតួនាទីប្រកបដោយការទទួលខុសត្រូវខ្ពស់ ដែលចូលរួមបន្ថែម មិនមែនកាត់បន្ថយប្រសិទ្ធភាពនៃការឆ្លើយតបចំពោះការរាតត្បាតជាសាកលនេះ។ វាជាការចាំបាច់ណាស់ដែលអ្នករាយការណ៍ពិសេស មិនត្រូវអនុវត្តការងារលើសព្រំដែននៃអាណត្តិរបស់ខ្លួន ដោយត្រូវគោរពអោយបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិ និងសៀវភៅណែនាំស្តីពីនីតិវិធីពិសេសនៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។

-----------------------

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា
នៅទីក្រុងហ្សឺណែវ សហព័ន្ធស្វីស

# សេចក្តីប្រកាសព័ត៌មាន

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា នៅហ្សឺណែវ ៖ "វិធានការប្រឆាំងនឹងការក្លែងព័ត៌មាន ពុំមែនជាការរិតត្បិតសេរីភាពទេ"

*ទីក្រុងហ្សឺណែវ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០* - ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅហ្សឺណែវ មានការខកចិត្តយ៉ាងខ្លាំងចំពោះសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវ និងបង្កអោយមានការភាន់ច្រឡំ របស់លោក David Kaye អ្នករាយការណ៍ពិសេសស្តីពីសេរីភាពនៃការបញ្ចេញមតិ (ហៅកាត់ថា អ្នករាយការណ៍ពិសេស) ពាក់ព័ន្ធនឹងការឆ្លើយតបចំពោះមេរោគកូវីដ១៩ របស់កម្ពុជា ដែលបានដាក់បញ្ចូលនូវគោលការណ៍សិទ្ធិមនុស្ស។

អ្នករាយការណ៍ពិសេសហាក់មិនត្រឹមតែពុំបានថ្កោលទោសការក្លែងព័ត៌មាន និងព័ត៌មានក្លែងក្លាយប៉ុណ្ណោះទេ ប៉ុន្តែបានលើកទឹកចិត្តឱ្យបន្តមាន "លំហូរព័ត៌មានដោយសេរី" ដែលរួមទាំងព័ត៌មានគ្រោះថ្នាក់ឬអន្តរាយទៀតផង។ វិធីសាស្ត្របែបនេះគឺងាកចេញពីគន្លងនៃវិធីសាស្ត្ររបស់ឯកឧត្តម António Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបានព្រមានអំពីគ្រោះថ្នាក់នៃព័ត៌មានក្លែងក្លាយ និងការប្រើប្រាស់សារស្អប់ខ្ពើម។ ទង្វើទាំងអស់នេះគឺជាការវាយប្រហារទៅលើខ្លឹមសារនៃបទដ្ឋាននិងគោលការណ៍សិទ្ធិមនុស្ស។ ហេតុដូចនេះហើយ ក្រុមការងារអង្គការសហប្រជាជាតិ កំពុងបង្កើនយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីកសាយនៃព័ត៌មានក្លែងក្លាយ។ មហាសន្និបាតសុខភាពពិភពលោកលើកទី៧៣ កាលពីខែឧសភា ឆ្នាំ២០២០ បានអនុម័តដោយកុងសង់ស៊ីសនូវសេចក្តីសម្រេចចិត្តស្តីពីការឆ្លើយតបនឹងមេរោគកូវីដ១៩ ដោយអំពាវនាវដល់រដ្ឋជាសមាជិកទាំងអស់ ចាត់វិធានការប្រឆាំងនឹងការក្លែងព័ត៌មាន និងព័ត៌មានមិនពិត។

ការឆ្លើយតបរបស់ប្រទេសកម្ពុជាចំពោះវិបត្តិសុខភាពនេះមានគោលបំណងធានាថា ជីវិតដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ជាពិសេសក្រុមងាយរងគ្រោះបំផុត នឹងមិនត្រូវបានបាត់បង់ដោយសារមេរោគកូវីដ១៩នោះឡើយ។ រាល់វិធានការដែលបានដាក់ចេញកន្លងមក បានគោរពតាមនីតិវិធីត្រឹមត្រូវ និងប្រកាន់ខ្ជាប់នូវគោលការណ៍នីត្យានុកូលភាព ភាពចាំបាច់ ភាពសមាមាត្រ និងពុំមានការរើសអើង។

ប្រទេសកម្ពុជាតែងតែគោរពផ្តល់តម្លៃសេរីភាពនៃការបញ្ចេញមតិនិងសារព័ត៌មានស្របច្បាប់ ហើយយល់ដឹងយ៉ាងច្បាស់ថា ពហុយោបល់ រួមទាំងទស្សនៈរិះគន់ គឺមានសារៈសំខាន់ចំពោះដំណើរការលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ខណៈពេលមេរោគកូវីដ១៩កំពុងកើនឡើង រាជរដ្ឋាភិបាលកម្ពុជាបាន



អាសយដ្ឋាន៖ 3 Chemin Taverney, Case Postale 213, 1218 Grand-Saconnex, Genève, Suisse
ទូរស័ព្ទ៖ (០៤១) ២២ ៧៨៨ ៧៧ ៧៣ អ៊ីម៉ែល៖ camemb.gva@mfaic.gov.kh គេហទំព័រ៖ http://www.cambodiaembassy.ch